# កង្កែបបានភ្លៀង

(បទពាក្យ៧)

ផ្គរលាន់គ្រឹមៗគ្រហឹមខ្ទ័រ
វាយោបក់ញ័រចុងរុក្ខា
រន្ទះបន្ទរចាករវេហាស៍
មេឃមីរអន្ធការត្រជាក់ប្រាណ។
ភ្លៀងធ្លាក់ស្រោចស្រក់តំណក់ធំ
ជនបទនិគមគ្រប់ទីឋាន
ត្រពាំបឹងថ្លុកជង្ហុកដាន
ប្រឡាយអូរបានទឹកល្អាចល្អ។
ហ៊ុំងហាងឆ្លើយឆ្លងនឹងកង្កែប
ហាវមាត់ច្រវែបបំប៉ោង ក
សប្បាយចិត្តណាស់ស្រែកអ៊ូអរ
ហែលទឹកឈ្វេឆរប្រលោមស្នេហ៍។
លោតចាក់កញ្ឆេងវែងរីករាយ
ហក់លេងអាយនាយស្រែកឡែៗ
ភ្លេចរន្ធភ្លេចរូងលែងនៅក្បែរ
រំភើបណាស់ដែរបានទឹកថ្មី។
ងប់ងក់វក់ញីស៊ីមេភ្លៀង
លង់ឈ្លក់ឆោមនាងកល្យាណី
ស្មានថាសួគ៌ានាលោកិយ
ស្ពាយឬករាប់ល្អីខំជំទាល។
ភ្លេចខ្លួនជូនចូលក្នុងសំណាញ់
គេបង់ វាយ បាញ់ ចាប់ដាក់ជាល
ចូលត្រក ចូលទ្រុងជាប់រង្គាល
ថ្លឹងគីឡូនាឡិ លក់តាមផ្សារ។
គេទិញគេដូរយកទៅធី
ស្ងោរ បោប ឆាខ្ញី ជ្រក់ក្លែមស្រា
ព្រោះតែសប្បាយភ្លេចកាយា
ក្សិណក្ស័យជីវាគួរអាសូរ។✍

(២៥ មករា ២០០២)

ភិក្ខុ ស្វាត សាលឿម